# ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១១២

## ស្តីពី

## ការប្រើប្រាស់ និងការការពារបដិរូបកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ៣៧៨/នស ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ១៩៥៨ ស្តីពីការទទួលស្គាល់សមាគមជាតិកាកបាទក្រហមកម្ពុជា
- បានទ្រង់យល់មាត្រា ២៦ នៃអនុសញ្ញាទីក្រុងហ្សឺណែវលើកទី ១ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ និងក្នុងកាតព្វកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងពិធីសារបន្ថែម ចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ១៩៧៧ រួមទាំងឧបសម្ព័ន្ធទី ១ នៃពិធីសារបន្ថែមទី ១ ដែលជាបទបញ្ជាស្តីពី ការសំគាល់អង្គភាព និងមធ្យោបាយដឹកជញ្ជូនផ្នែកវេជ្ជសាស្ត្រ
- បានទ្រង់យល់បទប្បញ្ញត្តិស្តីពី ការប្រើប្រាស់បដិរូបកាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម ដោយសមាគមជាតិ ដែលបានត្រូវអនុម័ត ដោយសន្និសីទអន្តរជាតិលើកទី ២០ នាឆ្នាំ ១៩៨២ របស់កាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ហើយនិងការកែប្រែបន្តបន្ទាប់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

# ព្រះរាជក្រឹត្យ

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១ .—

ព្រះរាជក្រឹត្យនេះ កំណត់ការប្រើប្រាស់ និងការការពារបដិរូបកាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម លើផ្ទាំងសំពត់ស រូបភាពកាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម និងសញ្ញាសំរាប់សំគាល់អង្គភាពនិងមធ្យោបាយដឹកជញ្ជូនផ្នែកវេជ្ជសាស្ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ .—

ក្នុងពេលមានជំលោះប្រដាប់អាវុធ បដិរូបដែលប្រើប្រាស់ជាឧបករណ៍សំរាប់ការពារ គឺជាសញ្ញាដែលគេមើលឃើញថាជាសញ្ញាការពារ ដូចដែលអនុសញ្ញាទីក្រុងហ្សឺណែវ និងពិធីសារបន្ថែមទាំងឡាយរបស់អនុសញ្ញា បានអនុញ្ញាតឱ្យបុគ្គលិកពេទ្យ ព្រមទាំងអង្គភាពនិងរថយន្តពេទ្យប្រើប្រាស់ ។ បដិរូបនេះ ត្រូវមានទំហំធំសមស្រប ។

បដិរូបដែលប្រើជាឧបករណ៍សំរាប់សំគាល់ បង្ហាញឱ្យដឹងថា មនុស្សឬវត្ថុមួយនោះ មានទំនាក់ទំនងទៅនឹងស្ថាប័នកាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម ។ ទំហំរបស់បដិរូបនេះ ត្រូវតូចល្មមសមស្រប ។

## ជំពូកទី ២

## ការប្រើប្រាស់បដិរូបសំរាប់ការពារ

មាត្រា ៣ .—

ការប្រើប្រាស់ដោយសេវាវេជ្ជសាស្ត្ររបស់កងកម្លាំងប្រដាប់អាវុធ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងការពារជាតិ សេវាកម្មវេជ្ជសាស្ត្ររបស់កងយោធពលខេមរភូមិន្ទ ត្រូវប្រើ បដិរូបកាកបាទក្រហម ដើម្បីកំណត់សំគាល់បុគ្គលិក អង្គភាព និងមធ្យោបាយដឹកជញ្ជូនរបស់ពេទ្យ តាមជើងគោក ជើងទឹក និងលើអាកាស ទាំងនៅពេលមានសន្តិភាព និងពេលមានជំលោះប្រដាប់អាវុធ ។

បុគ្គលិកពេទ្យកងយោធពលខេមរភូមិន្ទ ត្រូវពាក់ក្រណាត់ប៉ាន់ដៃនិងត្រូវមានអត្តសញ្ញាណប័ណ្ណសំគាល់ខ្លួន ដែលមានបដិរូបនៅលើនោះ ។ ក្រណាត់ប៉ាន់ដៃ និងអត្តសញ្ញាណប័ណ្ណទាំងនោះ ត្រូវផ្តល់ឱ្យដោយក្រសួងការពារជាតិ ។ បុគ្គលិកសាសនាដែលធ្វើការជាមួយកងទ័ព ត្រូវបានទទួលការការពារដូចជាបុគ្គលិកពេទ្យដែរ ហើយត្រូវមានសញ្ញាសំគាល់តាមរបៀបដូចគ្នានេះដែរ ។

មាត្រា ៤ .—

ដោយមានការអនុញ្ញាតទាន់ពេលវេលា និងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងសុខាភិបាល

នៅពេលមានជំលោះប្រដាប់អាវុធ បុគ្គលិកពេទ្យស៊ីវិល មន្ទីរពេទ្យនិងអង្គភាពពេទ្យស៊ីវិល ក៏ដូចជាយានជំនិះពេទ្យស៊ីវិលដែលបានទទួលការចាត់តាំងឱ្យដឹកជញ្ជូន និងព្យាបាលអ្នករបួស អ្នកជម្ងឺ និងអ្នកលង់ទឹកដោយសារកប៉ាល់លិច ត្រូវប្រើប្រាស់បដិរូបដែលប្រើជាឧបករណ៍ការពារ ។

បុគ្គលិកពេទ្យស៊ីវិល ត្រូវពាក់ក្រណាត់ប៉ាន់ដៃ និងត្រូវកាន់អត្តសញ្ញាណប័ណ្ណដែលមានបដិរូប ។ ក្រណាត់ប៉ាន់ដៃ និងអត្តសញ្ញាណប័ណ្ណទាំងនេះ ត្រូវផ្តល់ឱ្យដោយក្រសួងសុខាភិបាល ។

បុគ្គលិកស៊ីវិលខាងសាសនា ដែលធ្វើការអមជាមួយមន្ទីរពេទ្យ ហើយនិងអង្គភាពពេទ្យដទៃទៀត ត្រូវមានសញ្ញាសំគាល់តាមរបៀបដូចគ្នានេះដែរ ។

មាត្រា ៥ ៈ—

កាកបាទក្រហមកម្ពុជា ត្រូវបានអនុញ្ញាតឱ្យដាក់បុគ្គលិកពេទ្យ មន្ទីពេទ្យ និងមធ្យោបាយដឹកជញ្ជូនទៅតាមតម្រូវការប្រើប្រាស់នៃសេវាកម្មវេជ្ជសាស្ត្ររបស់កងទ័ព ។ បុគ្គលិកពេទ្យ មន្ទីរពេទ្យ និងមធ្យោបាយដឹកជញ្ជូនទាំងនោះ ត្រូវអនុវត្តច្បាប់និងបទបញ្ជាយោធា និងត្រូវបានទទួលការអនុញ្ញាតពីក្រសួងការពារជាតិឱ្យបំពាក់បដិរូបរបស់កាកបាទក្រហម ជាឧបករណ៍សំរាប់ការពារ ។

បុគ្គលិកពេទ្យទាំងនោះ ត្រូវពាក់ក្រណាត់ប៉ាន់ដៃ និងកាន់អត្តសញ្ញាណប័ណ្ណ ដូចមានចែងក្នុងមាត្រា ៣ កថាខ័ណ្ឌទី ២ នៃព្រះរាជក្រឹត្យនេះ ។

កាកបាទក្រហមកម្ពុជា អាចនឹងផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់បដិរូប ជាឧបករណ៍សំរាប់ការពារ, បុគ្គលិកពេទ្យ និងអង្គភាពពេទ្យរបស់ខ្លួន ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៣
## ការប្រើប្រាស់បដិរូបសំរាប់សំគាល់

មាត្រា ៦ —

កាកបាទក្រហមកម្ពុជា បានទទួលការអនុញ្ញាតឱ្យប្រើប្រាស់បដិរូប ជាឧបករណ៍សំរាប់បង្ហាញឱ្យឃើញថា មនុស្ស ឬវត្ថុមួយនោះ មានទំនាក់ទំនងទៅនឹងកាកបាទក្រហមកម្ពុជា ។ បដិរូបប្រើសំគាល់បែបនេះ ត្រូវមានទំហំតូចល្មម ដើម្បីជៀសវាងការភាន្តច្រឡំ ដែលអាចកើតឡើងជាមួយនឹងបដិរូបដែលប្រើជាឧបករណ៍សំរាប់ការពារ ។

កាកបាទក្រហមកម្ពុជា ត្រូវអនុវត្តបទបញ្ជានានាស្តីពី ការប្រើប្រាស់បដិរូបរបស់កាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម ។

ដោយមានការឯកភាពជាមុនពីកាកបាទក្រហមកម្ពុជា សមាគមជាតិកាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហមនៃប្រទេសផ្សេងទៀត ដែលស្ថិតនៅលើទឹកដីនៃប្រទេសកម្ពុជា ត្រូវប្រើបដិរូបតាមល័ក្ខខ័ណ្ឌដូចគ្នានេះដែរ ។

## ជំពូកទី ៤
## ការប្រើប្រាស់បដិរូបអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហមអន្តរជាតិ

មាត្រា ៧ .—

គណៈកម្មាធិការអន្តរជាតិកាកបាទក្រហម និងសហព័ន្ធអន្តរជាតិនៃសមាគមជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម អាចប្រើប្រាស់បដិរូបបានគ្រប់ពេលវេលា និងក្នុងគ្រប់សកម្មភាពរបស់ខ្លួន ។

## ជំពូកទី ៥
## ការប្រើប្រាស់មិនត្រឹមត្រូវនូវបដិរូប កាកបាទក្រហម ឬ អឌ្ឍច័ន្ទក្រហម

មាត្រា ៨ .—

អាជ្ញាធរកម្ពុជា ជានិច្ចកាលត្រូវធានាឱ្យមានការអនុវត្តយ៉ាងម៉ឺងម៉ាត់ នូវវិធានស្ដីពីការគ្រប់គ្រងការប្រើប្រាស់បដិរូបកាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម ការប្រើឈ្មោះ កាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម ព្រមទាំងសញ្ញាសំគាល់ទាំងឡាយ ។ អាជ្ញាធរ ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់ ការត្រួតពិនិត្យមនុស្សទាំងឡាយដែលបានទទួលការអនុញ្ញាតឱ្យប្រើបដិរូប ឈ្មោះ និងសញ្ញាសំគាល់ ។

អាជ្ញាធរ ត្រូវចាត់វិធានការសមស្រប ដើម្បីបង្ការនូវការប្រើខុស ជាពិសេសត្រូវធ្វើការផ្សព្វផ្សាយអំពីវិធានដែលបានលើកមកនេះ ឱ្យបានទូលំទូលាយតាមដែលអាចធ្វើបាន ក្នុងចំណោមកងកម្លាំងប្រដាប់អាវុធ កងកម្លាំងនគរបាល អាជ្ញាធរសាធារណៈ និងពលរដ្ឋស៊ីវិល ។

មាត្រា ៩ .—

កាកបាទក្រហមកម្ពុជា ត្រូវសហការយ៉ាងសកម្មជាមួយនឹងអាជ្ញាធរសមត្ថកិច្ច នៅក្នុងការខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបង្ការ និងបង្ក្រាបការប្រើខុសណាមួយ ។ កាកបាទក្រហមកម្ពុជា ត្រូវបានផ្ដល់សិទ្ធិឱ្យជូនដំណឹងទៅរាជរដ្ឋាភិបាល អំពីការប្រើខុសណាមួយ ព្រមទាំងចូលរួមក្នុងការប្ដឹងតាមផ្លូវច្បាប់ ឬតាមផ្នែករដ្ឋបាលដែលពាក់ព័ន្ធ ។

## ជំពូកទី ៦
## ការចុះបញ្ជីឈ្មោះរបស់សមាគមជាតិ ឈ្មោះពាណិជ្ជកម្ម និងនិក្ខិតសញ្ញា

មាត្រា ១០ .—

ការចុះបញ្ជីឈ្មោះរបស់សមាគមជាតិ-ឈ្មោះពាណិជ្ជកម្មនានា និងការចុះនិក្ខិតសញ្ញា សញ្ញាសំគាល់ផ្នែកពាណិជ្ជកម្ម និងគំរូផ្នែកឧស្សាហកម្ម និងការប្រើប្រាស់ ការគូរបដិរូបកាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម ឬការប្រើឈ្មោះថា កាកបាទក្រហម ឬ អឌ្ឍច័ន្ទក្រហម ត្រូវបានហាមឃាត់ ។

មានតែកាកបាទក្រហមកម្ពុជាតែមួយគត់ ដែលអាចចុះបញ្ជីសុំការប្រើប្រាស់បដិរូបកាកបាទក្រហម បាន ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ១១.—**

ជនណាដែលធ្វើតាមទំនើងចិត្ត ដោយពុំមានការអនុញ្ញាតត្រឹមត្រូវ ពុំមានការផ្តល់សិទ្ធិប្រើប្រាស់ បដិរូបកាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម ពាក្យ កាកបាទក្រហម ឬ អឌ្ឍច័ន្ទក្រហម សញ្ញាសំគាល់ ឬសញ្ញាផ្សេងណាមួយ រូបភាព ឬសញ្ញាក្លែងបន្លំ ឬដែលអាចធ្វើឱ្យមានការភ័ន្តច្រឡំ ដោយមិនគិតទៅដល់ គោលបំណងនៃការប្រើនេះ ហើយជាពិសេស ជនណាដែលបានយកបដិរូប ឬយកពាក្យនេះទៅដាក់លើសញ្ញាសំគាល់ ផ្សេងៗដូចជា ប័ណ្ណប្រែសណីយ៍ ប័ណ្ណប្រកាស ក្រដាសផ្សព្វផ្សាយ ឬឯកសារពាណិជ្ជកម្ម ឬបានបិទភ្ជាប់បដិរូប ឬពាក្យទាំងនោះលើទំនិញ ឬលើកញ្ចប់ ឬបានលក់ ឬផ្តល់ឱ្យសំរាប់ដាក់លក់ ឬដាក់ក្នុងចរាចរទំនិញ នឹងត្រូវ ផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន ។

ប្រសិនបើការរំលោភបំពាននេះ បានធ្វើឡើងដោយការដឹកនាំរបស់អង្គភាពសហគ្រាស ក្រុមហ៊ុន/ សមាគមណាមួយ ការផ្តន្ទាទោស នឹងត្រូវអនុវត្តទៅលើបុគ្គលណាដែលបានធ្វើការរំលោភបំពាននេះ ឬទៅលើបុគ្គល ណាដែលបានបញ្ជាឱ្យមានការរំលោភបំពាននេះ ។

**មាត្រា ១២.—**

ជនណាដែលគ្មានការអនុញ្ញាតត្រឹមត្រូវ បានធ្វើតាមទំនើងចិត្ត ឬបានចេញបញ្ជាឱ្យធ្វើរហូតដល់ បណ្តាលឱ្យស្លាប់ ឬបណ្តាលឱ្យមានរបួសជាទម្ងន់ទៅលើខ្លួនប្រាណ ឬប៉ះពាល់សុខភាពរបស់គូសត្រូវ ដោយប្រើប្រាស់ ដោយទុច្ចរិតនូវបដិរូបរបស់កាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម ឬសញ្ញាសំគាល់ គឺជាការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ។ ការប្រព្រឹត្ត បែបនេះ នឹងត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន ។

ការប្រើប្រាស់ដោយទុច្ចរិតមានន័យថា មានគោលបំណងបោកប្រាស់គូសត្រូវ ឬដែលនាំឱ្យបុគ្គល នោះជឿជាក់ថា ជនទុច្ចរិតនេះបានទទួលសិទ្ធិក្នុងការទទួល ឬមានកាតព្វកិច្ចការពារ ដែលវិធានទាំងឡាយរបស់ ច្បាប់មនុស្សធម៌អន្តរជាតិ បានផ្តល់ឱ្យ ។

**មាត្រា ១៣.—**

ដោយហេតុថា ការភាន់ច្រឡំអាចនឹងកើតមានឡើងរវាងបដិរូបរបស់ប្រទេសស្វីស និងបដិរូប កាកបាទក្រហម ការប្រើប្រាស់សញ្ញាកាកបាទពណ៌សនៅលើផ្ទៃពណ៌ក្រហម ឬសញ្ញាណាដែលធ្វើប្រដូច ទោះបីជា និក្ខិតសញ្ញា ឬសញ្ញាពាណិជ្ជកម្ម ឬជាសមាសភាគមួយនៃសញ្ញាទាំងនេះ ឬក្នុងគោលបំណងប្រឆាំងនឹងពាណិជ្ជកម្ម

ស្មើភាព ឬក្នុងស្ថានភាពសំដៅធ្វើឱ្យប៉ះពាល់ដល់មនោសញ្ចេតនាជាតិរបស់ស្វីស ត្រូវបានហាមឃាត់ ហើយអ្នកដែលបានប្រព្រឹត្តបទល្មើស នឹងត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន ។

**មាត្រា ១៤.–**

ការរឹបអូសយកវត្ថុ និងសំភារៈនានាដែលត្រូវបានប្រើប្រាស់ ការដកឬលុបចោលបដិរូបរបស់កាកបាទក្រហម ឬ អឌ្ឍច័ន្ទក្រហម និងពាក្យ កាកបាទក្រហម ឬ អឌ្ឍច័ន្ទក្រហម ការតម្រូវឱ្យប៉ះប៉ូវសោហ៊ុយខូចខាត និងការកំទេចគ្រឿងឧបករណ៍ដែលប្រើប្រាស់សំរាប់ការផលិតចម្លងបដិរូបនេះ ជាសមត្ថកិច្ចរបស់តុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ១៥.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៦.–

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ ២០០២

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

ពរល.០២.០៥.០០១៤២

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

លេខ: ៦១១ ក.អ
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០២
អគ្គលេខាធិការរាជរដ្ឋាភិបាល